ធ៧-០៩-២១៦ ប្រ.ក

# ប្រកាស
# ស្តីពី
# ការផ្តល់របាយការណ៍ឥណទានធំ និង
# ពិនិត្យតាមដានហានិភ័យឥណទានប្រមូលផ្តុំ

## ជំពូក ១
## បទប្បញ្ញត្តិទូទៅ

**ប្រការ ១**.-

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ តទៅនេះហៅថា គ្រឹះស្ថាន ត្រូវពិនិត្យឡើងវិញឱ្យបានហ្មត់ចត់ ប្រចាំត្រីមាស នូវឥណទានធំបំផុតចំនួន ៥០។ គ្រឹះស្ថាន ត្រូវសម្រប និងលើកកំពស់គុណភាពប្រព័ន្ធគ្រប់គ្រងព័ត៌មានរបស់ខ្លួន ដើម្បីប្រតិបត្តិតាមកាតព្វកិច្ចដែលមានចែងក្នុងប្រកាសនេះ។

**ប្រការ ២**.-

ហានិភ័យឥណទានប្រមូលផ្តុំអាចមានផលប៉ះពាល់ធ្ងន់ធ្ងរ ដល់ស្ថានភាពហិរញ្ញវត្ថុរបស់គ្រឹះស្ថាន ដូច្នេះ តម្រូវឱ្យមានការពិនិត្យតាមដានជាពិសេស ដើម្បីវាយតម្លៃផលប៉ះពាល់ជាសក្តានុពលនៃការធ្លាក់ចុះស្ថានភាពអ្នកខ្ចីធំៗ ក្នុងកាលៈទេសៈដែលសេដ្ឋកិច្ចមិនអំណោយផល។

លើសពីនេះ ទោះបីមានបទប្បញ្ញត្តិទាក់ទងនឹងហានិភ័យឥណទានធំក្តី ក៏ហានិភ័យឥណទានប្រមូលផ្តុំ ត្រូវតែសមស្របទៅនឹងហានិភ័យដែលអាចទទួលយកបាន និងភាពរឹងមាំនៃស្ថានភាពហិរញ្ញវត្ថុរបស់គ្រឹះស្ថាន។ ហានិភ័យឥណទានដែលត្រូវបានចាត់ទុកថាប្រមូលផ្តុំខ្លាំងពេក តម្រូវឱ្យមានការវាយតម្លៃឡើងវិញនូវគោលនយោបាយ និងកម្រិតកំណត់ឥណទានជាបន្តបន្ទាប់ និងប្រចាំគ្រា។

**ប្រការ ៣**.-

រាល់ត្រីមាស គ្រឹះស្ថាន ត្រូវផ្តល់ឱ្យសមាជិកក្រុមប្រឹក្សាភិបាល ឬសមាជិកគណៈប្រតិបត្តិនូវបញ្ជីអ្នកខ្ចីធំបំផុត ជាឯកត្តជន ឬជាក្រុម ចំនួនហាសិប (៥០)។ របាយការណ៍នេះ ត្រូវមានជាអប្បបរមានូវទិន្នន័យ និងព័ត៌មានទាំងអស់ ដែលតម្រូវដោយធនាគារជាតិនៃកម្ពុជា។

គ្រឹះស្ថាន ត្រូវផ្តល់ឱ្យសមាជិកក្រុមប្រឹក្សាភិបាល ឬសមាជិកគណៈប្រតិបត្តិ នូវការវាយតម្លៃសង្ខេបអំពីស្ថានភាពហិរញ្ញវត្ថុជារួមរបស់អ្នកខ្ចី ជាពិសេស បើឥណទានត្រូវបានធ្វើចំណាត់ថ្នាក់មិនល្អ រាល់ឯកសារភស្តុតាង ដែលមានទិន្នន័យ និងព័ត៌មានគ្រប់គ្រាន់ ត្រូវបានប្រគល់ជូនសមាជិកក្រុមប្រឹក្សាភិបាល ឬសមាជិកគណៈប្រតិបត្តិ ដើម្បីវាយតម្លៃអំពីសក្តានុពលនៃការខាតបង់ និងផលប៉ះពាល់ផ្សេងទៀត ជាពិសេស អំពីស្ថានភាពសាច់ប្រាក់ងាយស្រួល និងសាធនភាពរបស់គ្រឹះស្ថាន។

របាយការណ៍ប្រចាំត្រីមាសទាំងនេះ ត្រូវមានបញ្ជាក់អំពីវិធានការណ៍ទាំងអស់ដែលគ្រឹះស្ថានបាន និងត្រូវអនុវត្តដើម្បីការពារផលប្រយោជន៍របស់គ្រឹះស្ថាន។

## ជំពូក ២
## ការរួមបញ្ចូលគ្នានូវហានិភ័យ

**ប្រការ ៤**.-

នៅពេលដែលឯកត្តជន ឬនីតិបុគ្គលពីរ ឬច្រើនត្រូវបានចាត់ទុកជាអ្នកខ្ចីតែមួយ ដោយសារតែមានទំនាក់ទំនងទៅវិញទៅមក គ្រឹះស្ថានត្រូវបូកសរុបហានិភ័យទាំងអស់ឱ្យបានត្រឹមត្រូវ និងវាយលំអិតអ្នកខ្ចីនីមួយៗ និងកម្រិតអនុម័តឥណទានដែលបង្កើតបានជាហានិភ័យរួមបញ្ចូលគ្នា។

**ប្រការ ៥**.-

ត្រូវបានចាត់ទុកថាជាអត្ថគាហកតែមួយ គឺក្រុមបុគ្គលដែលមានចំណងទាក់ទងទៅវិញទៅមក ដែលប្រសិនបើបុគ្គលមួយឬច្រើនជួបបញ្ហាហិរញ្ញវត្ថុនោះ នឹងនាំឱ្យបុគ្គលផ្សេងទៀតត្រូវតែមានបញ្ហាហិរញ្ញវត្ថុធ្ងន់ធ្ងរផងដែរ។

ជាពិសេស ចំណងទាក់ទងបែបនេះកើតមានរវាងបុគ្គលពីរ ឬច្រើននៅពេលណាដែល ៖

ក- បុគ្គលណាមួយគ្រប់គ្រងដោយផ្ទាល់ ឬដោយប្រយោលលើបុគ្គលផ្សេងទៀត

ខ- បុគ្គលទាំងឡាយណាដែលជាបុត្តសម្ព័ន្ធរបស់ក្រុមហ៊ុនមេតែមួយ

គ- បុគ្គលទាំងឡាយណាដែលស្ថិតនៅក្រោមការគ្រប់គ្រងតាមព្រឹត្តន័យ(de facto management)

ឃ- បុគ្គលណាមួយមានភាគហ៊ុននៅក្នុងក្រុមហ៊ុនផ្សេងទៀតលើសពីដប់ភាគរយ(១០%) ហើយ ពួកគេត្រូវបានចងភ្ជាប់ដោយកិច្ចសន្យាធានាបដិការឬមានទំនាក់ទំនងអាជីវកម្មពិសេសជាមួយគ្នាដូចជា កិច្ចសន្យាបន្តសិទ្ធិប្រើយីហោ (franchise)។ល។

ធនាគារជាតិនៃកម្ពុជា អាចចាត់ទុកអតិថិជនមួយក្រុមថាជាអត្ថគាហកតែមួយបើចំណងទាក់ទងរបស់ពួកគេមានដូចខាងលើ។

**ប្រការ ៦**.-

លើសពីនេះ គ្រឹះស្ថានអាចកំណត់នូវកត្តាពាក់ព័ន្ធផ្នែកសេដ្ឋកិច្ច ឬទំនាក់ទំនងទៅវិញទៅមកផ្សេងទៀត ជាពិសេសដោយផ្អែកលើការវិភាគប្រភពដើម និងការប្រមូលផ្តុំនៃលំហូរសាច់ប្រាក់។

**ប្រការ ៧**.-

គ្រឹះស្ថាន ត្រូវរួមបញ្ចូលគ្នានូវហានិភ័យទាំងអស់ឱ្យបានសមស្រប ដើម្បីឆ្លុះបញ្ចាំងអំពីស្ថានភាពហានិភ័យទាំងមូលទៅលើសំណុំកូនបំណុលដែលមានទំនាក់ទំនងជាមួយគ្នាជាអ្នកខ្ចីតែមួយ។

## ជំពូក ៣
## ទម្រង់ និងខ្លឹមសារ នៃរបាយការណ៍

**ប្រការ ៨**.-

គ្រឹះស្ថានត្រូវរាយការណ៍តាមគំរូរបាយការណ៍ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ។ របាយការណ៍នេះ ត្រូវតែមានខ្លឹមសារគ្រប់គ្រាន់អាចទទួលយកបាន។ ហានិភ័យឥណទានធំបំផុតចំនួន ៥០ ត្រូវតែបានបង្ហាញតាមលំដាប់ចំនួនប្រាក់ថយចុះ។

**ប្រការ ៩**.-

រូបវន្តបុគ្គល និងនីតិបុគ្គលទាំងឡាយដែលត្រូវបានចាត់ទុកជាអ្នកខ្ចីតែមួយ ត្រូវតែសម្គាល់អត្តសញ្ញាណឱ្យបានច្បាស់លាស់ និងត្រូវតែបញ្ជាក់អំពីប្រភេទនៃទំនាក់ទំនងទៅវិញទៅមក។ ព័ត៌មានលំអិតអំពីទំនាក់ទំនង ក្នុងចំណោមសមាសភាពទាំងឡាយនៃក្រុមអ្នកខ្ចី ត្រូវមានឧបសម្ព័ន្ធភ្ជាប់មកជាមួយរបាយការណ៍។

ព័ត៌មានអំពីអត្តសញ្ញាណទាំងនោះត្រូវមានជាអប្បបរមា ដូចខាងក្រោម ៖

- រូបវន្តបុគ្គលៈ នាមនិងគោត្តនាមទាំងអស់ដែលប្រើជាផ្លូវការ ថ្ងៃខែឆ្នាំកំណើត អាសយដ្ឋាន មុខរបរ/វិជ្ជាជីវៈ និង វិស័យសេដ្ឋកិច្ច
- នីតិបុគ្គលៈ នាមករណ៍ យីហោ លេខចុះបញ្ជីពាណិជ្ជកម្ម ថ្ងៃបង្កើតក្រុមហ៊ុន អាសយដ្ឋានក្រុមហ៊ុន មុខរបរ វិស័យសេដ្ឋកិច្ច និងព័ត៌មានផ្សេងទៀត ដើម្បីបញ្ជាក់ភាពត្រឹមត្រូវនៃអត្តសញ្ញាណ។

មុនពេលរួមបញ្ចូលហានិភ័យរបស់នីតិបុគ្គល និង/ឬរូបវន្តបុគ្គលដែលត្រូវបានចាត់ថាជាអ្នកខ្ចីតែមួយ គ្រឹះស្ថានត្រូវវាយលំអិតបុគ្គលនីមួយៗតាមកម្រិតអនុម័តឥណទានទាំងអស់។

ការរួមបញ្ចូលគ្នាត្រូវអនុវត្តដោយបូកសរុបដោយឡែកពីគ្នារវាងសមតុល្យដក់សល់ដុលក្នុងតារាងតុល្យការ និងសមតុល្យជាប់កិច្ចសន្យានៃខ្ទង់ក្រៅតារាងតុល្យការ។

**ប្រការ ១០**.-

ចំនួនហានិភ័យឥណទានក្នុងតារាងតុល្យការត្រូវតែរាយការណ៍ដោយប្រើចំនួនដុល ដែលជាចំនួនប្រាក់ដើមដក់សល់ ដោយមិនបញ្ចូលសំវិធានធនជាក់លាក់ និងការប្រាក់លើកលែងតែការប្រាក់នោះត្រូវបានបូកបញ្ចូលជាប្រាក់ដើមដូចមានចែងក្នុងកិច្ចសន្យា។

ហានិភ័យឥណទានធំត្រូវបានវាយលំអិតតាមកម្រិតអនុម័តឥណទាននិងតាមអ្នកខ្ចីនីមួយៗ។ ព័ត៌មានអប្បបរមាដែលត្រូវមាន គឺប្រភេទហានិភ័យ (ឥណទានវិបារូបន៍ ឬឥណទាន) ប្រាក់ដើមដក់សល់ ចំនួនប្រាក់ដែលបានអនុម័តដំបូង ប្រភេទនៃការរំលោះ និងកាលវសាន្ត។

បើកម្រិតអនុម័តឥណទានឬអ្នកខ្ចីត្រូវបានចាត់ថ្នាក់មិនល្អ នៅក្នុងកិច្ចបញ្ជិកាគណនី និងកំណត់ត្រារបស់គ្រឹះស្ថាន របាយការណ៍ត្រូវឆ្លុះបញ្ចាំងក្នុងខ្ទង់ដោយឡែកពីគ្នានូវការចាត់ថ្នាក់ដែលសមស្រប និងការបង្កើតសំវិធានធនជាក់លាក់លើហានិភ័យនោះ។

**ប្រការ ១១**.-

ហានិភ័យក្រៅតារាងតុល្យការត្រូវតែបានរាយការណ៍ ដោយបូកបញ្ចូលនូវចំនួនសមតុល្យជាប់កិច្ចសន្យា ដែលនៅសល់នាកាលបរិច្ឆេទរាយការណ៍។

កម្រិតអនុម័តឥណទាននោះ ត្រូវតែបានវាយលំអិតតាមអត្ថគាហកនីមួយៗ ហើយឆ្លុះបញ្ចាំងពីចំនួនសមតុល្យជាប់កិច្ចសន្យាដែលនៅសល់ ចំនួនប្រាក់ដែលបានអនុម័តដំបូង និងពីកាលវសាន្តបើមាន ហើយត្រូវតែមានបញ្ជាក់ច្បាស់អំពីប្រភេទប្រតិបត្តិការ (ឥណទានវិបារូបន៍ដែលមិនបានប្រើ ការសន្យាឥណទានដែលមិនទាន់បានប្រើប្រាស់ ការធានានិងប្រភេទនៃការធានា)។

បើកម្រិតអនុម័តឥណទានឬអ្នកខ្ចីត្រូវបានចាត់ថ្នាក់មិនល្អ នៅក្នុងកិច្ចបញ្ជិកាគណនី និងកំណត់ត្រារបស់គ្រឹះស្ថាន របាយការណ៍ត្រូវឆ្លុះបញ្ចាំងក្នុងខ្ទង់ដោយឡែកពីគ្នានូវការចាត់ថ្នាក់ដែលសមស្រប និងការបង្កើតសំវិធានធនជាក់លាក់លើហានិភ័យនោះ។

## ជំពូក ៤
## កាលបរិច្ឆេទនៃរបាយការណ៍

**ប្រការ ១២**.-

គ្រឹះស្ថានទាំងអស់ ត្រូវផ្ញើរបាយការណ៍អំពីហានិភ័យឥណទានធំបំផុតចំនួន ៥០ ប្រចាំត្រីមាសគិតត្រឹមចុងខែមិនា មិថុនា កញ្ញា និងធ្នូ មកធនាគារជាតិនៃកម្ពុជា ឱ្យបានមុនថ្ងៃទី១៥ ខែទីមួយ នៃត្រីមាសបន្ទាប់។

## ជំពូក ៥
## ទណ្ឌកម្ម

**ប្រការ ១៣**.-

គ្រឹះស្ថានដែលមិនគោរពតាមខ្លឹមសារនៃប្រកាសនេះ នឹងត្រូវរងទណ្ឌកម្មខាងវិន័យដូចមានចែងក្នុងមាត្រា ៥២ នៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

## ជំពូក ៦
## អវសានប្បញ្ញត្តិ

**ប្រការ ១៤**.-

ប្រកាសនេះមិនអនុវត្តចំពោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុឡើយ។

**ប្រការ ១៥**.-

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គាធិការដ្ឋាន អគ្គបេឡា និងគ្រប់នាយកដ្ឋាន អង្គភាពគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅក្រោមឱវាទ និងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

**ប្រការ ១៦**.-

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៩

**ទេសាភិបាល**

ហត្ថលេខា និងត្រា: **ជា ចាន់តូ**